## Self-Executing Treaty Provisions

១. ទ្រឹស្តីអនុវត្តដោយស្វ័យប្រវត្តិ (self-executing: SE) ត្រូវបានអភិវឌ្ឍជាដំបូង ដោយតុលាការ កំពូលអាមេរិក ហើយក្រោយមក ត្រូវបានប្រកាន់យកដោយយុត្តាធិការជាច្រើន។ តុលាការអឺរ៉ុបប្រើពាក្យ "ការអនុវត្តសន្ធិសញ្ញាដោយផ្ទាល់" ជំនួសពាក្យ "SE"។ វាមានន័យថា សន្ធិសញ្ញាបង្កើតសិទ្ធិ និងកាតព្វកិច្ចសម្រាប់បុគ្គល ហើយអាចសំអាងបទប្បញ្ញត្តិ នៅមុខតុលាការ ឬអាជ្ញាធរដែលត្រូវតែអនុវត្តសន្ធិសញ្ញានោះ។

២. ក្នុងន័យនេះ មិនមែនគ្រប់សន្ធិសញ្ញាទាំងអស់ អាចត្រូវបានអនុវត្តដោយផ្ទាល់ទេ ហើយការកំណត់ថាសន្ធិសញ្ញាមួយណា អាចអនុវត្តផ្ទាល់ ឬមិន វាអាស្រ័យទៅតាមការបកស្រាយសន្ធិសញ្ញា ឬការកំណត់ក្នុងច្បាប់ជាតិជាពិសេសសម្រាប់ប្រទេសប្រកាន់លំនាំ Dualist។ ដើម្បីអាចអនុវត្តផ្ទាល់បាន វាទាមទារនូវលក្ខខណ្ឌមួយចំនួនដូចជា៖ សន្ធិសញ្ញា ត្រូវបានបម្លែងជាទៅផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិ តាមរយៈច្បាប់ (transformation act) ឬខ្លឹមសារនៃសន្ធិសញ្ញាត្រូវតែជាក់លាក់។

៣. ក្នុងករណីខ្លះ ផ្នែកខ្លះនៃសន្ធិសញ្ញា អាចត្រូវចាត់ថា មិនអាចអនុវត្តផ្ទាល់ តាមបញ្ញត្តិបដិសេធ (exclusion clause) ដូចជាបទប្បញ្ញត្តិស្តីពី ការដោះស្រាយជម្លោះ ដែលទុកសមត្ថកិច្ចជូនតុលាការអន្តរជាតិជាដើម។ ភាពអាចអនុវត្តដោយផ្ទាល់ អាចត្រូវបានបដិសេធដោយ សភា។ សន្ធិសញ្ញា មិនអាចអនុវត្តដោយផ្ទាល់មានដូចជាសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង បង្កើតកាតព្វកិច្ច ឬសិទ្ធិទៅវិញទៅមករវាងរដ្ឋ ឬ មិនចងជាកាតព្វកិច្ច (non-binding agreement)។ បន្ថែមពីលើនេះ សន្ធិសញ្ញាខ្លះ ទាមទារនូវការធ្វើច្បាប់ដើម្បីអាចអនុវត្តបាន (implementing act) ដូចនេះវាមិនមែនជា សន្ធិសញ្ញា SE ទេ។

៤. ជាចុងក្រោយ ការប្រើប្រាស់នូវសន្ធិសញ្ញា ទោះបីមិនទាន់ក្លាយជាផ្នែក នៃប្រព័ន្ធច្បាប់ជាតិ សម្រាប់បកស្រាយច្បាប់ជាតិ ឬ ដោះស្រាយបញ្ហាច្បាប់អន្តរជាតិ ក្នុងជម្លោះមុខតុលាការជាតិ មិនទាមទារថាសន្ធិសញ្ញានោះ អាចត្រូវបានអនុវត្តដោយផ្ទាល់ ឬមិនផ្ទាល់ទេ។

ដកស្រង់ចេញពី Albert Bleckman, Self-Executing Treaty Provisions ក្នុង Max Planck Institute for Comparative Public Law and International Law, Encyclopedia of Public International Law, Vol. IV, 2000, pp. 374-377

**កំណត់សំគាល់**៖ ទ្រឹស្តី SE ត្រូវបានទទួលយកផងដែរ ដោយយុត្តាធិការនៃប្រទេសប្រកាន់ប្រព័ន្ធស៊ីវិលឡូ។ អ្នកស្រាវជ្រាវខ្លះ បានស្នើឲ្យពិនិត្យមើល ចេតនារបស់អ្នកធ្វើសេចក្តីព្រាងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ឬបទប្បញ្ញត្តិនៃអត្ថបទ ដែលអាចសរសេរយ៉ាងជាក់លាក់នូវប្រភេទនៃសន្ធិសញ្ញា។ ទោះបីជាយ៉ាងនេះក្តី វាកម្រឃើញមានសន្ធិសញ្ញា ចែងដូចនេះណាស់។ ដូចអត្ថបទខាងលើបានបញ្ជាក់ ជួនកាល សន្ធិសញ្ញាទាំងមូល ឬមានតែបទប្បញ្ញត្តិមួយចំនួនប៉ុណ្ណោះនៃសន្ធិសញ្ញានោះ អាចអនុវត្តផ្ទាល់បាន។ តុលាការជប៉ុន បានបកស្រាយពាក្យ "គ្មានជនណាម្នាក់" ក្នុងមាត្រា ១៧ នៃកតិកាសញ្ញា ស្តីពីសិទ្ធិប្រជាពលរដ្ឋ ថាផ្តល់សិទ្ធិផ្ទាល់ដល់បុគ្គល។ ដូចនេះ បទប្បញ្ញត្តិនេះ អាចអនុវត្តដោយផ្ទាល់បាន។[1] ផ្ទុយទៅវិញ មាត្រា ៤ នៃអនុសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម មិនមែនជាបទប្បញ្ញត្តិអាចអនុវត្តផ្ទាល់បានភ្លាមទេ សម្រាប់ប្រទេសប្រកាន់ប្រព័ន្ធស៊ីវិលឡូ ដែលមិនទាន់បានបង្កើតច្បាប់ ចាត់អំពើទារុណកម្មជាបទល្មើសព្រហ្មទណ្ឌ។[2]

នេះដើម្បីតម្រូវតាមគោលការណ៍នីត្យានុកូលភាព http://www.measboralaws.com/detail/738

---

[1] គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។ Shi Hae Bong, *Japan*, in Dinah Shelton, International Law and Domestic Legal Systems, Incorporation, Transformation, and Persuasion, 2011, p. 369.,

[2] 1. Each State Party shall ensure that all acts of torture are offences under its criminal law. The same shall apply to an attempt to commit torture and to an act by any person which constitutes complicity or participation in torture. 2. Each State Party shall make these offences punishable by appropriate penalties which take into account their grave nature, UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, 10 December 1984, United Nations, Treaty Series, vol. 1465, p. 85, available at: https://www.refworld.org/docid/3ae6b3a94.html [accessed 23 May 2020]